ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរពីប្រទេសម៉ាឡេស៊ី ថៃ និងចិន**

* * * * * *

១- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរឈ្មោះ **រ.ណ** អាយុ៣៤ឆ្នាំ មានស្រុកកំណើតនៅខេត្តព្រៃវែង ដែលបានទៅធ្វើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ី ពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ពលការិនីត្រូវបាននិយោជករបស់ខ្លួន នាំទៅប្រគល់ជូនស្ថានទូត ដោយសារពលការិនីមានចិត្តមិនស្មោះត្រង់។ តាមសំណើរបស់ស្ថានទូត និយោជករបស់ពលការិនី បានប្រគល់ប្រាក់ខែដែលនៅសល់ លិខិតឆ្លងដែន និងសំបុត្រយន្តហោះដល់ពលការិនីនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៦។

ពលការិនី **រ.ណ** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** ហើយ នៅថ្ងៃទី**០៩** ខែ **វិច្ឆិកា ឆ្នាំ២០១៦** វេលាម៉ោង**១៦:០០**នាទី តាមជើងយន្តហោះលេខAK534។ អំឡុងពេលរង់ចាំមកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនីផងដែរ។

២- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានសម្របសម្រួលមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរម្នាក់ដែលមានសតិមិនប្រក្រតី ឈ្មោះ **ស.ស.រ** អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅខេត្តបាត់ដំបង។ បុរសរូបនេះ បានទៅធ្វើការសំណង់នៅប្រទេសថៃជាច្រើនឆ្នាំមកហើយ ដោយពុំមានឯកសារសំគាល់អត្តសញ្ញាណជាប់ខ្លួនទេ។ គាត់ត្រូវបានអ្នកបើកបររថយន្តតាក់ស៊ីជនជាតិថៃម្នាក់ ជួយជូនដំណើរទៅកាន់ស្ថានទូត។

ស្ថានទូតបានផ្តល់សំលៀកបំពាក់ថ្មី អាហារបរិភោគ និងចេញឯកសារធ្វើដំណើរបណ្តោះអាសន្នដល់គាត់ ហើយបានចាត់អោយបុគ្គលិកស្ថានទូត ជូនមកកម្ពុជាវិញតាមច្រកទ្វារអន្តរជាតិ**ប៉ោយប៉ែត** នៅថ្ងៃទី**០៩** ខែ**វិច្ឆិកា ឆ្នាំ២០១៦** និងស្នើស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ទាក់ទងជាមួយអាជ្ញាធរក្រុងប៉ោយប៉ែត អោយទទួល និងជូនដំណើរពលរដ្ឋខាងលើទៅដល់ស្រុកកំណើតវិញ។

៣- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិន បានសហការជាមួយប៉ូលីសចិន ជួយសង្គ្រោះនារីខ្មែរម្នាក់ឈ្មោះ **ភ.ភ** អាយុ១៨ឆ្នាំ មានស្រុកកំណើតនៅខេត្តកណ្តាល ដែលត្រូវបានមេខ្យល់លួងលោមយកទៅធ្វើការនៅប្រទេសចិន តែក្រោយមកតម្រូវអោយរៀបការជាមួយបុរសជនជាតិចិន។

នារីរងគ្រោះខាងលើ នឹងមកដល់ព្រលានយន្តហោះអន្តរជាតិភ្នំពេញ នៅថ្ងៃទី**១១** ខែ**វិច្ឆិកា** ឆ្នាំ**២០១៦** វេលាម៉ោង**១៧:៤០** នាទី តាមជើងយន្តហោះលេខKA206 ។

ភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ